PESTECH

# សេចក្តីជូនដំណឹង
## ស្តីពី
## កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក របស់ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក

**ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក ("ផថខ")** សូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិក វិនិយោគិន និងសាធារណជនឲ្យបានជ្រាបថា អនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣ កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកនឹងប្រព្រឹត្តនៅ **ថ្ងៃពុធ ១០ រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧** ត្រូវនឹង **ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅវេលាម៉ោង ១០:០០ ព្រឹក។**

របៀបវារៈលម្អិតនៃកិច្ចប្រជុំមានដូចខាងក្រោម៖

| | | |
|---|---|---|
| កាលបរិច្ឆេទសម័យប្រជុំ | ៖ | ថ្ងៃពុធ ទី៨ ខែវិច្ឆិកា ឆ្នាំ២០២៣ |
| កាលបរិច្ឆេទកំណត់ទុក | ៖ | ថ្ងៃចន្ទ ទី១៦ ខែតុលា ឆ្នាំ២០២៣ |
| ទីកន្លែងប្រជុំ | ៖ | សណ្ឋាគារត្រាយប៍ភ្នំពេញ (TRIBE Phnom Penh Hotel) បន្ទប់ស្ទូឌីអូ (The Studio Room) ជាន់ R ផ្ទះលេខ៤៧ ផ្លូវលេខ១ កែងផ្លូវលេខ៩៤ ភូមិ៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |

| ពេលវេលា | របៀបវារៈ |
|---|---|
| | |
| ៩:០០ ព្រឹក - ១០:០០ ព្រឹក | **សុន្ទរកថាបើកកម្មវិធី** |
| | ការចុះវត្តមានភាគហ៊ុនិក |
| | ការបង្ហាញអំពីរបៀបវារៈនៃកិច្ចប្រជុំ និងបទបង្ហាញស្តីពីដំណើរការនៃការបោះឆ្នោត |
| ១០:០០ ព្រឹក - ១០:១៥ ព្រឹក | មតិស្វាគមន៍ដោយ លោក Paul Lim Pay Chuan ប្រធានក្រុមប្រឹក្សាភិបាលនៃ **ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក** |
| ១០:១៥ ព្រឹក - ១១:០០ ព្រឹក | របាយការណ៍សមិទ្ធផលអាជីវកម្មប្រចាំឆ្នាំនៃចុងបញ្ចប់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ |
| | វគ្គសំណួរ និងចម្លើយ |
| | **ការអនុម័តលើសេចក្តីសម្រេច** |


**ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក** (លេខចុះបញ្ជី៖ ០០០០០៩៥៧)

(ក្រុមហ៊ុន PESTECH)

អគារលេខ ៣៥ ជាន់ទី១០ មហាវិថីម៉ៅសេទុង ភូមិ០៩ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ +៨៥៥ ២៣ ៨៨២ ១០៥ ទូរសារ +៨៥៥ ២៣ ៨៨២ ១០៦ គេហទំព័រ៖ www.pestech-international.com

| | | |
|---|---|---|
| ១១:០០ ព្រឹក - ១១:៥០ ព្រឹក | សេចក្តីសម្រេច ១ | ការអនុម័តលើលាភការរបស់ក្រុមប្រឹក្សាភិបាល |
| | សេចក្តីសម្រេច ២ | ការអនុម័តលើការបន្តអាណត្តិ Mr. Paul Lim Pay Chuan ជាប្រធានក្រុមប្រឹក្សាភិបាលប្រតិបត្តិ ដោយអនុលោមតាមមាត្រា ១៨.១ នៃលក្ខន្តិក:ក្រុមហ៊ុន |
| | សេចក្តីសម្រេច ៣ | ការអនុម័តលើការបន្តអាណត្តិ Mr. Han Fatt Juan ជាអភិបាលប្រតិបត្តិ និងជានាយកប្រតិបត្តិ ដោយអនុលោមតាមមាត្រា ១៨.១ នៃលក្ខន្តិក:ក្រុមហ៊ុន |
| | សេចក្តីសម្រេច ៤ | ការអនុម័តលើការបន្តអាណត្តិ Mr. Lim Ah Hock ជាអភិបាលប្រតិបត្តិ ដោយអនុលោមតាមមាត្រា ១៨.១ នៃលក្ខន្តិក:ក្រុមហ៊ុន |
| | សេចក្តីសម្រេច ៥ | ការអនុម័តលើការបោះឆ្នោតជ្រើសរើស លោក ដាវ៉ អានសាន ជាអភិបាលឯករាជ្យមិនប្រតិបត្តិ ដោយអនុលោមតាមមាត្រា ១៨.១ នៃលក្ខន្តិក:ក្រុមហ៊ុន |
| | សេចក្តីសម្រេច ៦ | ការអនុម័តលើការមិនបែងចែកភាគលាភសម្រាប់ឆ្នាំហិរញ្ញវត្ថុដែលបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ |
| | សេចក្តីសម្រេច ៧ | ការអនុម័តលើសិទ្ធិប្រកាសបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទដែលនឹងបញ្ចប់គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ |
| | សេចក្តីសម្រេច ៨ | សិទ្ធិក្នុងការបោះផ្សាយភាគហ៊ុនដោយយោងតាមលក្ខន្តិក:ក្រុមហ៊ុន<br><br>"***សម្រេចថា*** កម្មវត្ថុដែលនៅតែមានចំពោះច្បាប់សហគ្រាសពាណិជ្ជកម្ម លក្ខន្តិក: ក្រុមហ៊ុន និងការឯកភាពពីនិយ័តករមូលបត្រកម្ពុជា ("នមក") ផ្សារមូលបត្រកម្ពុជា ("ផមក") រដ្ឋាភិបាល និង/ឬអាជ្ញាធរពាក់ព័ន្ធផ្សេងៗ តាមរយៈនេះអភិបាល ដែលបានទទួលសិទ្ធស្របច្បាប់ សូមចេញ និងបែងចែកភាគហ៊ុននៅក្នុងដើមទុនរបស់ក្រុមហ៊ុនពីមួយគ្រាទៅមួយគ្រានូវតម្លៃណាមួយ និងយោងទៅតាមលក្ខខណ្ឌនានាសម្រាប់គោលបំណងផ្សេងៗ និងចំពោះបុគ្គលម្នាក់ ឬច្រើនណាក៏ដោយ អភិបាលអាចមានសិទ្ធសម្រេចតាមឆន្ទានុសិទ្ធិសមស្របទាំងស្រុងរបស់ពួកគាត់ |

PESTECH

| | | |
|---|---|---|
| | | ***និងសម្រេចថា*** អភិបាលក៏ត្រូវបានផ្ដល់នូវសិទ្ធអំណាចផងដែរដើម្បីទទួលបាននូវ ការអនុម័តចំពោះការលក់មូលបត្រភាគហ៊ុន និងការដាក់តម្លៃភាគហ៊ុនបន្ថែម ក៏ដូចជាការចេញលក់នៅលើ ផមក ផងដែរ និងធ្វើការផ្លាស់ប្តូរលើលក្ខន្តិកៈក្រុមហ៊ុនឲ្យស្របគ្នា។<br><br>***និងសម្រេចបន្ថែមថា*** ការផ្ដល់សិទ្ធអំណាចនេះ នឹងចាប់ផ្ដើមសម្រេចភ្លាមៗដោយ យោងតាមការអនុម័តនៃសេចក្ដីសម្រេចនេះ និងបន្តអនុវត្តរហូតដល់កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិករបស់ក្រុមហ៊ុននាពេលក្រោយ"។ |
| ១១:៥០ ព្រឹក - ១២:៣០ រសៀល | **ដំណើរការបោះឆ្នោត និងលទ្ធផលបោះឆ្នោត** | |
| | ប្រមូលសន្លឹកឆ្នោត | |
| | សម្រាកទទួលទានកាហ្វេ | |
| | ការប្រកាសលទ្ធផលបោះឆ្នោត | |
| | បញ្ចប់កិច្ចប្រជុំ | |

**កំណត់សម្គាល់នៃការពន្យល់សេចក្ដីសម្រេច៖**

### សេចក្ដីសម្រេច ១ - ការអនុម័តលើលាភការរបស់ក្រុមប្រឹក្សាភិបាល

សេចក្ដីសម្រេចនេះត្រូវបានដាក់លើការអនុម័តលាភការរបស់ក្រុមប្រឹក្សាភិបាលដែលរួមទាំងអភិបាលប្រតិបត្តិ ចំនួន ៣ រូប និងអភិបាលឯករាជ្យមិនប្រតិបត្តិចំនួន ១ រូប។ មិនមានការប្រែប្រួលលើលាភការរបស់ក្រុមប្រឹក្សាភិបាលនោះទេ។ ក្នុងករណីសេចក្ដីសម្រេចនេះត្រូវបានអនុម័ត នោះរយៈពេលអនុវត្តគឺចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។

### សេចក្ដីសម្រេច ២ ដល់ សេចក្ដីសម្រេច ៤ - ការអនុម័តលើការបន្តអាណត្តិអភិបាលប្រតិបត្តិជាថ្មី

សេចក្ដីសម្រេចនេះត្រូវរៀបចំឡើងដើម្បីអនុម័តលើការបន្តអាណត្តិជាថ្មីរបស់ លោក Paul Lim Pay Chuan លោក Han Fatt Juan និងលោក Lim Ah Hock ដោយអនុលោមតាមមាត្រា ១៨.១ នៃលក្ខន្តិកៈក្រុមហ៊ុន។

ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក (លេខចុះបញ្ជី៖ ០០០០០៩៥៧)
(ក្រុមហ៊ុន PESTECH)
អគារលេខ ៣៥ ជាន់ទី១០ មហាវិថីម៉ៅសេទុង ភូមិ០៩ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ +៨៥៥ ២៣ ៨៨២ ១០៥ ទូរសារ +៨៥៥ ២៣ ៨៨២ ១០៦ គេហទំព័រ៖ www.pestech-international.com

ក្នុងមាត្រា១៨.១នៃលក្ខន្តិកៈក្រុមហ៊ុន អភិបាលត្រូវតែបោះឆ្នោតជ្រើសតាំងដោយសេចក្តីសាមញ្ញរបស់ភាគហ៊ុនិក។ លុះត្រាតែមានចែងក្នុងសេចក្តីសម្រេច អភិបាលនីមួយៗត្រូវបានបោះឆ្នោតជ្រើសតាំងសម្រាប់អាណត្តិដែលមានរយៈពេល ពីរ (២) ឆ្នាំ និងអាចត្រូវបានបោះឆ្នោតជ្រើសតាំងបន្តទៀត។

លោក Paul Lim Pay Chuan លោក Han Fatt Juan និងលោក Lim Ah Hock ត្រូវបានឆ្នោតជ្រើសតាំងបន្តអាណត្តិកាលពីកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិករបស់ក្រុមហ៊ុនដែលបានប្រព្រឹត្តឡើងនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១។ ដូចដែលបានរៀបរាប់ អាណត្តិរយៈពេល ពីរ (២)ឆ្នាំ របស់លោកនឹងត្រូវបញ្ចប់ដែលតម្រូវឲ្យមានការបោះឆ្នោតជ្រើសតាំងបន្តអាណត្តិនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៣។

ក្នុងករណីសេចក្តីសម្រេចទាំងនេះត្រូវបានអនុម័ត លោក Paul Lim Pay Chuan លោក Han Fatt Juan និងលោក Lim Ah Hock នឹងបន្តអាណត្តិជាអភិបាលក្នុងក្រុមប្រឹក្សាភិបាលហើយមានអនុភាពអនុវត្តភ្លាមបន្ទាប់ពីកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិករបស់ក្រុមហ៊ុនត្រូវបានបញ្ចប់។

**សេចក្តីសម្រេច ៥ - ការអនុម័តលើការបោះឆ្នោតជ្រើសរើស លោក ដាវ អានសាន ជាអភិបាលឯករាជ្យមិនប្រតិបត្តិ**

សេចក្តីសម្រេចនេះត្រូវរៀបចំឡើងដើម្បីអនុម័តលើការបោះឆ្នោតជ្រើសរើស លោក ដាវ អានសាន ជាអភិបាលឯករាជ្យមិនប្រតិបត្តិ អនុលោមតាមមាត្រា ១៨.១ នៃលក្ខន្តិកៈក្រុមហ៊ុន។

កាលពីកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិករបស់ក្រុមហ៊ុនដែលបានប្រព្រឹត្តឡើងនៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២២ លោក ដាវ អានសាន ត្រូវបានអនុម័តឲ្យបន្តជាអភិបាលក្រុមហ៊ុន ហើយអាណត្តិរបស់លោកនឹងត្រូវបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។

ក្នុងមាត្រា១៨.១នៃលក្ខន្តិកៈក្រុមហ៊ុន អភិបាលត្រូវតែបោះឆ្នោតជ្រើសតាំងដោយសេចក្តីសាមញ្ញរបស់ភាគហ៊ុនិក។ លុះត្រាតែមានចែងក្នុងសេចក្តីសម្រេច អភិបាលនីមួយៗត្រូវបានបោះឆ្នោតជ្រើសតាំងសម្រាប់អាណត្តិដែលមានរយៈពេល ពីរ (២) ឆ្នាំ និងអាចត្រូវបានបោះឆ្នោតជ្រើសតាំងបន្តទៀត។

ក្នុងករណីសេចក្តីសម្រេចនេះត្រូវបានអនុម័ត លោក ដាវ អានសាន នឹងបន្តអណត្តិជាអភិបាលក្នុងក្រុមប្រឹក្សាភិបាលហើយមានអានុភាពអនុវត្តភ្លាម ដែលអាណត្តិរបស់លោកនឹងមានរយៈពេលរហូតដល់ បី (៣) ឆ្នាំ ដែលត្រូវផុតកំណត់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៦។

ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក (លេខចុះបញ្ជី៖ ០០០០០៩៥៧)
(ក្រុមហ៊ុន PESTECH)
អគារលេខ ៣៥ ជាន់ទី១០ មហាវិថីម៉ៅសេទុង ភូមិ០៩ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ +៨៥៥ ២៣ ៨៨២ ១០៥ ទូរសារ +៨៥៥ ២៣ ៨៨២ ១០៦ គេហទំព័រ៖ www.pestech-international.com

PESTECH

## សេចក្តីសម្រេច ៦ - ការអនុម័តលើការមិនបែងចែកភាគលាភសម្រាប់ឆ្នាំហិរញ្ញវត្ថុដែលបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣

**ផថខ** បានកត់ត្រាខាតសុទ្ធចំនួន ២៣ ២៤៦ លានរៀល តំណាងឲ្យការថយចុះចំនួន ២៥ ៧១៦ លានរៀល បើប្រៀបធៀបនឹងចំណេញសុទ្ធសម្រាប់ក្នុងឆ្នាំហិរញ្ញវត្ថុដែលបានបញ្ចប់នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ ដែលមានចំនួន ២ ៤៧០ លានរៀល។ ក្រុមប្រឹក្សាភិបាលនៃ **ផថខ** បានស្នើមិនឲ្យបែងចែកភាគលាភសម្រាប់ឆ្នាំហិរញ្ញវត្ថុដែលបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ ក្រោមហេតុផលនៃការខាតបង់។

## សេចក្តីសម្រេច ៧ - ការអនុម័តលើសិទ្ធិប្រកាសបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទដែលនឹងបញ្ចប់គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤

ស្របតាមគោលនយោបាយភាគលាភ ក្រុមហ៊ុនមានបំណងបែងចែកភាគលាភអប្បបរមាចំនួន (៣០%) នៃប្រាក់ចំណេញរបស់ខ្លួនបន្ទាប់ពីកាត់ពន្ធរួចដោយយោងទៅលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របាយការណ៍សាច់ប្រាក់ ប្រាក់ចំណេញរក្សាទុកចំណាយមូលធន និងកត្តាផ្សេងទៀតដែលក្រុមប្រឹក្សាភិបាលគិតថាជាប់ពាក់ព័ន្ធ។

ក្រុមហ៊ុនសម្ល័ន្ធអាចពិចារណាបែងចែកភាគលាភជាសាច់ប្រាក់ ជាភាគហ៊ុនសម្រាប់ឱកាសវិនិយោគឡើងវិញនៅក្នុងក្រុមហ៊ុន ឬជម្រើសទាំងពីរខាងលើរួមគ្នា។

សេចក្តីសម្រេចនេះ ប្រសិនបើបានអនុម័តនឹងអនុញ្ញាតឱ្យក្រុមប្រឹក្សាភិបាលស្នើសុំ និងប្រកាសភាគលាភពីមួយគ្រាទៅមួយគ្រាតាមអត្រា និងល័ក្ខខ័ណ្ឌដូចដែលក្រុមប្រឹក្សាភិបាលអាចសំរេចតាមឆន្ទានុសិទ្ធិសមស្របទាំងស្រុងរបស់ពួកគាត់។ តាមរយៈការផ្តល់សិទ្ធនេះ លុះត្រាតែក្រុមហ៊ុនលុបចោល ឬផ្លាស់ប្តូរក្នុងកិច្ចប្រជុំមហាសន្និបាទ នោះនឹងត្រូវផុតកំណត់នៅពេលបញ្ចប់កិច្ចប្រជុំមហាសន្និបាទម្ចាស់ភាគហ៊ុនិករបស់ក្រុមហ៊ុននាពេលក្រោយ។

## សេចក្តីសម្រេច ៨ - សិទ្ធិក្នុងការបោះផ្សាយភាគហ៊ុនដោយយោងតាមលក្ខន្តិកៈក្រុមហ៊ុន

សេចក្តីសម្រេចដែលបានស្នើសុំ ប្រសិនបើបានឆ្លងការសម្រេច ផ្តល់លភាពងាយស្រួលដល់អភិបាលដើម្បីបោះផ្សាយភាគហ៊ុនសកម្មភាពរួមជាអាទិ៍ ការដាក់ភាគហ៊ុនសម្រាប់ការផ្តល់មូលនិធិគម្រោងវិនិយោគនាពេលអនាគតរបស់ ក្រុមហ៊ុន ការវិនិយោគ និង/ឬ ការទិញភាគហ៊ុនតាមរយៈ ការចេញភាគហ៊ុននៅក្នុងក្រុមហ៊ុនចំពោះបុគ្គលនៅពេលណាក៏បានតាមដែលអភិបាលចាត់ទុកថាសមស្របដោយមិនចាំបាច់មានការកោះប្រជុំទូទៅ។ តាមរយៈសិទ្ធិអំណាចនេះ លុះត្រាតែក្រុមហ៊ុនបានលុបចោល ឬផ្លាស់ប្តូរក្នុងកិច្ចប្រជុំមហាសន្និបាទ នោះនឹងត្រូវផុតកំណត់នៅពេលបញ្ចប់កិច្ចប្រជុំមហាសន្និបាទម្ចាស់ភាគហ៊ុនិករបស់ក្រុមហ៊ុននាពេលបន្ទាប់។ អភិបាលត្រូវផ្តល់សិទ្ធិអំណាច


**ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក** (លេខចុះបញ្ជី៖ ០០០០០៩៥៧)

(ក្រុមហ៊ុន **PESTECH**)

អគារលេខ ៣៥ ជាន់ទី១០ មហាវិថីម៉ៅសេទុង ភូមិ០៩ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ +៨៥៥ ២៣ ៨៨២ ១០៥ ទូរសារ +៨៥៥ ២៣ ៨៨២ ១០៦ គេហទំព័រ៖ www.pestech-international.com

PESTECH

ដើម្បីទទួលបានការយល់ព្រមសម្រាប់ការចុះបញ្ជី និងសម្រង់តម្លៃភាគហ៊ុនបន្ថែមដែលបានចេញនៅលើ ផមក និង ដើម្បីធ្វើការផ្លាស់ប្តូរលើលក្ខន្តិកៈក្រុមហ៊ុនទៅតាមនោះ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣

**ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក**

ព្រះរាជាណាចក្រកម្ពុជា
ផេសថិក
(ខេមបូឌា) ម.ក
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក (លេខចុះបញ្ជី៖ ០០០០០៩៥៧)

(ក្រុមហ៊ុន PESTECH)

អគារលេខ ៣៥ ជាន់ទី១០ មហាវិថីម៉ៅសេទុង ភូមិ០៩ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ +៨៥៥ ២៣ ៨៨២ ១០៥ ទូរសារ +៨៥៥ ២៣ ៨៨២ ១០៦ គេហទំព័រ៖ www.pestech-international.com

PESTECH

**សម្គាល់៖**

១. ភាគហ៊ុននិកមានឈ្មោះក្នុងបញ្ជីភាគហ៊ុនិកដែលបានកត់ត្រានៅថ្ងៃចន្ទ ទី១៦ ខែតុលា ឆ្នាំ២០២៣ នឹងទទួលបានការអញ្ជើញតាមរយៈមធ្យោបាយអេឡិចត្រូនិក ឬតាមរយៈភ្នាក់ងារផ្ទេរមូលបត្រដែលបានតែងតាំង។

២. បន្ទាប់ពីទទួលបានការអញ្ជើញដូចបានជម្រាបជូនខាងលើ ភាគហ៊ុនិកត្រូវបញ្ជាក់ពីការចូលរួមរបស់ខ្លួនទៅកាន់ **ធនាគារ អេស៊ីលីដា ភីអិលស៊ី** តាមរយៈមធ្យោបាយអេឡិចត្រូនិក ឬតាមរយៈភ្នាក់ងារផ្ទេរមូលបត្ររបស់ខ្លួនចាប់ពី ថ្ងៃចន្ទទី១៦ ខែតុលា ឆ្នាំ២០២៣ ដល់ថ្ងៃចន្ទ ទី៦ ខែវិច្ឆិកា ឆ្នាំ២០២៣។

៣. ក្នុងករណីដែលភាគហ៊ុនិកណាម្នាក់ពុំអាចចូលរួមកិច្ចប្រជុំមហាសន្និបាតដោយផ្ទាល់ទេនោះ ភាគហ៊ុនិករូបនោះអាចតែងតាំងបុគ្គលណាម្នាក់ផ្សេងទៀតអោយធ្វើជាអ្នកតំណាងរបស់ខ្លួនដើម្បីចូលរួមកិច្ចប្រជុំនោះបាន។

៤. ឯកសារបែបបទរបស់អ្នកតំណាងនឹងត្រូវផ្ញើរជូនភាគហ៊ុនិកជាមួយ និងសេចក្តីជូនដំណឹងស្តីពីកិច្ចប្រជុំមហាសន្និបាត។ ភាគហ៊ុនិក ឬអ្នកតំណាងត្រូវផ្ញើឯកសារបែបបទរបស់អ្នកតំណាងនោះទៅ **ធនាគារ អេស៊ីលីដា ភីអិលស៊ី** អោយបានត្រឹម ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២៣ តាមរយៈមធ្យោបាយអេឡិចត្រូនិច ឬតាមរយៈភ្នាក់ងារផ្ទេរមូលបត្រដែលខ្លួនបានតែងតាំង។

៥ ភាគហ៊ុននិកដែលពុំបានបញ្ជាក់អំពីការអញ្ជើញចូលរួម ឬពុំបានផ្តល់ឯកសារបែបបទអ្នកតំណាងដល់ **ធនាគារ អេស៊ីលីដា ភីអិលស៊ី** ឬភ្នាក់ងារផ្ទេរមូលបត្រតាមកាលបរិច្ឆេទកំណត់ខាងលើនឹងមិនត្រូវបានអនុញ្ញាតឱ្យចូលរួមកិច្ចប្រជុំមហាសន្និបាតរបស់ ផថខ ឡើយ។

៦ សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមកកាន់ **ធនាគារ អេស៊ីលីដា ភីអិលស៊ី** ឬ **ផថខ** ដូចខាងក្រោម៖


**ធនាគារ អេស៊ីលីដា ភីអិលស៊ី**

**លោក ហួត សុភី** AVP និងប្រធានផ្នែកប្រតិបត្តិការ RTP
ទូរស័ព្ទ៖ (៨៥៥) ១៥ ៩០០ ៥៣៨
អ៊ីម៉ែល៖ huot.sophy@acledabank.com.kh

**លោក កែន រិទ្ធពុទ្ធា** អ្នកឯកទេសបឋមប្រតិបត្តិការ RTP
ទូរស័ព្ទ៖ (៨៥៥) ១៥ ៨០០ ៦៦៣
អ៊ីម៉ែល៖ ken.rithputhea@acledabank.com.kh

**លោកស្រី សំរិទ្ធ វណ្ណីបុប្ផារង្សី** ប្រធានផ្នែកប្រតិបត្តិការ RTP
ទូរស័ព្ទ៖ (៨៥៥) ៦១ ២៨៧ ៧៦៦
អ៊ីម៉ែល៖ op.rtp@acledabank.com.kh

**ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក**

**លោកស្រី Lynda Pan** លេខាធិកាក្រុមហ៊ុន
ទូរស័ព្ទ៖ (៨៥៥) ២៣ ៨៨២ ១០៥
អ៊ីម៉ែល៖ info@pestech.com.kh

**កញ្ញា ពិន សុគន្ធទេវី** ជំនួយការបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន
ទូរស័ព្ទ៖ (៨៥៥) ៧៧ ៣៨៣ ១៩១
អ៊ីម៉ែល៖ pinsokuntevy@pestech.com.kh